# ស្ថានភាពអតិផរណានៅខែវិច្ឆិកា ឆ្នាំ២០១៥

*******

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ បានថយចុះចំនួន **០,២%** ធៀបនឹងខែមុន ប៉ុន្តែ បានកើនឡើង **១,៩%** ធៀបនឹង១២ខែមុន។ សន្ទស្សន៍ថ្លៃថយចុះធៀបនឹងខែមុន មានដូចជា សន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត បានថយចុះចំនួន ១,៣% សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំបានថយចុះ ០,៣% សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានថយចុះ ១,៥% សន្ទស្សន៍ថ្លៃគមនាគមន៍បានថយចុះ ០,១% និងសន្ទស្សន៍ថ្លៃទំនិញផ្សេងៗទៀតបានថយចុះ ០,៤%។ ទន្ទឹមនឹងនេះ ក៏មានសន្ទស្សន៍ថ្លៃទំនិញមួយចំនួនទៀតមានការកើនឡើង ដូចជា សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ មានការកើនឡើង ២,៦% ក្នុងនោះថ្លៃថ្នាំជក់បានកើនឡើង ៤,២% និងស្រាបៀរ បានកើនឡើង ០,៨% សន្ទស្សន៍ថ្លៃសុខាភិបាល មានការកើនឡើង ០,៤% ក្នុងនោះថ្លៃផលិតផលថ្នាំពេទ្យ និងប្រដាប់ប្រដាប្រើប្រាស់បាន កើនឡើង ០,៥% និងថ្លៃសេវាសុខាភិបាលក្រៅមន្ទីរពេទ្យ បានកើនឡើង ០,១% និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋានមានការកើនឡើង ១,១%។

ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង១២ក្រុមមានដូចខាងក្រោម÷

| | ខែមុន | ១២ខែមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **-០,២** | **+១,៩** |
| ១-អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | ០,០ | +៤,៣ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +២,៦ | +៧,១ |
| ៣-សំលៀកបំពាក់និងស្បែកជើង | -០,៧ | +៥,២ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | -១,៣ | -៣,៦ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ | -០,៣ | +៣,១ |
| ៦-សុខាភិបាល | +០,៤ | +១,៩ |
| ៧-ការដឹកជញ្ជូន | -១,៥ | -៨,៥ |
| ៨-គមនាគមន៍ | -០,១ | ០,២ |
| ៩-ការកំសាន្ត និងវប្បធម៌ | ០,០ | +១,៩ |
| ១០-ការសិក្សា | ០,០ | +០,៦ |
| ១១-ភោជនីយដ្ឋាន | +១,១ | +៦,៨ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,៤ | -១,២ |

ទោះជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបប្រចាំឆ្នាំ បានធ្លាក់ចុះទាបត្រឹម ១,៩% គិតមកត្រឹមខែវិច្ឆិកា នេះ ប៉ុន្តែ បើមិនគិតសន្ទស្សន៍ថ្លៃក្រុមទី៤ និងទី៧ ដែលពាក់ព័ន្ធទៅនឹងការចុះថ្លៃប្រេងឥន្ធនៈដ៏គំហុកនោះ គឺសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុបប្រចាំឆ្នាំមានកំណើនធំជាង ៤%។ កត្តានេះ បណ្តាលមកពីការកើនឡើងសន្ទស្សន៍ថ្លៃម្ហូបអាហារ និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន ដោយសារការថយចុះផលនេសាទ ការផ្ទុះជម្ងឺឆ្លងក្នុងវិស័យបសុសត្វ និងអាកាសធាតុមិនសូវអំណោយផលល្អក្នុងការដាំដុះ ។ តាមការសង្កេត និន្នាការសន្ទស្សន៍ថ្លៃម្ហូបអាហារ និងសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន នៅតែមានកំណើនខ្ពស់ និងអាចបន្តកើនឡើងនៅឆ្នាំខាងមុខទៀត បើសិនជាកត្តាប្រឈមខាងលើនៅអូសបន្លាយ ។

តាមការធ្វើចំណោលគិតដល់ខែធ្នូ ឆ្នាំ២០១៥ អតិផរណាប្រចាំឆ្នាំ (year on year)អាចមានអត្រា ២,៤ % ឬ អតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ១,២%។

| តារាងប្រៀបធៀបបម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារមួយចំនួនប្រចាំឆ្នាំ២០១៤-២០១៥ (គិតជា %) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| មុខទំនិញ | ២០១៤ | | | | | ២០១៥ | | | | |
| | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា |
| អង្ករ | 1.2 | 1.4 | 1.3 | 1.3 | **1.1** | 2.5 | 2.0 | 2.5 | 2.1 | **2.9** |
| សាច់គោ | 7.0 | 7.3 | 6.9 | 7.1 | **5.6** | 1.8 | 0.6 | 1.3 | 1.7 | **5.1** |
| សាច់មាន់ | 5.2 | 4.5 | 3.9 | 3.2 | **3.6** | 1.2 | 1.9 | 2.2 | 2.5 | **3.6** |
| សាច់ទា | 4.3 | 4.9 | 4.5 | 4.0 | **5.1** | 3.8 | 2.7 | 2.8 | 3.0 | **3.2** |
| សាច់ជ្រូក | 12.0 | 11.1 | 10.1 | 9.2 | **8.8** | 1.2 | 1.0 | 1.1 | 1.1 | **3.5** |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 7.4 | 5.3 | 4.6 | 2.6 | **2.1** | 6.8 | 7.3 | 7.3 | 7.9 | **10.2** |
| ក្នុងនោះត្រីស្រស់ | 8.1 | 5.5 | 4.8 | 2.7 | **1.8** | 8.0 | 8.6 | 8.6 | 8.7 | **11.3** |
| ផ្លែឈើ | 11.4 | 12.4 | 9.7 | 6.3 | **9.5** | 1.2 | 1.1 | 2.0 | 5.2 | **1.9** |
| ផ្លែឈើស្រស់ | 13.1 | 14.5 | 11.3 | 7.0 | **11.0** | 2.4 | 2.1 | 3.2 | 7.2 | **2.9** |
| បន្លែ | -0.9 | 2.6 | 1.6 | -0.2 | **1.2** | 8.3 | 7.4 | 7.6 | 8.6 | **4.8** |
| បន្លែជាស្លឹក | -4.8 | 1.2 | -1.2 | -4.8 | **-2.4** | 9.6 | 8.8 | 8.7 | 10.6 | **4.7** |
| បន្លែជាផ្លែ | 5.2 | 8.2 | 7.8 | 7.2 | **10.4** | 14.8 | 10.8 | 12.3 | 10.7 | **4.3** |
| ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ | | | | | | | | | | |

## ៦/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

តារាងឧបសម្ព័ន្ធ៣÷ អតិផរណាប្រចាំឆ្នាំ (ជាភាគរយ)

| ប្រទេស | ២០១៤ | | | ២០១៥ | | |
|---|---|---|---|---|---|---|
| | សីហា | កញ្ញា | វិច្ឆិកា | សីហា | កញ្ញា | វិច្ឆិកា |
| ប្រទេសកម្ពុជា | 3.5 | 2.9 | 2.4 | 0.9 | 1.3 | 1.9 |
| ប្រទេសវៀតណាម | 3.6 | 3.2 | 2.6 | 0.0 | -0.01 | 0.3 |
| ប្រទេសថៃ | 1.7 | 1.5 | 1.3 | -1.0 | -0.7 | -0.9 |
| ប្រទេសម៉ាឡេស៊ី | 2.6 | 2.8 | 3.0 | 2.6 | 2.5 | 2.6 |
| ប្រទេសឥណ្ឌូនេស៊ី | 4.5 | 4.8 | 6.2 | 6.8 | 6.3 | 4.9 |
| ប្រទេសភីលីពីន | 4.4 | 4.3 | 3.7 | 0.3 | 0.4 | 1.1 |
| ប្រទេសចិន | 1.6 | 1.6 | 1.4 | 0.0 | -0.3 | 0.1 |
| ប្រទេសកូរ៉េខាងត្បូង | 1.1 | 1.2 | 1.0 | 0.5 | 0.9 | 1.0 |
| ប្រទេសជប៉ុន | 3.2 | 2.9 | 2.4 | 0.0 | 0.3 | 0.3 |

**កំណត់សម្គាល់៖** ប្រភពទិន្នន័យ(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**រៀបចំ និង ធ្វើចំណោលដោយ**

**នាយដ្ឋានស្ថិតិ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**